ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ០០១ សណន

# សេចក្តីណែនាំ
# ស្តីពី
# នីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ា និងសំណើ សំណូមពរ ក្រោមក្របខ័ណ្ឌគម្រោងធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្លាស្ទិកនៅប្រទេសកម្ពុជា

អនុលោមតាមអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ប្រកាសលេខ២០៤៨ ប្រក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតអង្គភាពគ្រប់គ្រងគម្រោងធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្លាស្ទិកនៅកម្ពុជាក្រោមក្របខ័ណ្ឌហិរញ្ញប្បទានពីធនាគារពិភពលោក ប្រកាសលេខ៣៣១៤ ប្រក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសគាំទ្រការអនុវត្តគម្រោងធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្លាស្ទិកនៅប្រទេសកម្ពុជា ក្រោមក្របខ័ណ្ឌហិរញ្ញប្បទានពីធនាគារពិភពលោក និងកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ រវាងរាជរដ្ឋាភិបាល និងធនាគារពិភពលោក ដែលតម្រូវឱ្យអង្គភាពអនុវត្តគម្រោងរៀបចំយន្តការដោះស្រាយបណ្តឹងតវ៉ា និងសំណើ សំណូមពររបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនឹងការអនុវត្តគម្រោង ក្រសួងមហាផ្ទៃដែលជាស្ថាប័នទទួលបន្ទុកអនុវត្តសមាសភាគទី២ នៃគម្រោងធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្លាស្ទិកនៅប្រទេសកម្ពុជា សូមធ្វើការណែនាំដល់រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់គោលដៅនៃគម្រោងដូចខាងក្រោម៖

## ១. វិសាលភាព

សេចក្តីណែនាំស្តីពីនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ា និងសំណើ សំណូមពររបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធមានវិសាលភាពអនុវត្តចំពោះ៖

- រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ដែលជាគោលដៅនៃការអនុវត្តគម្រោងធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្លាស្ទិកនៅប្រទេសកម្ពុជា
- បណ្តឹងតវ៉ា និងសំណើ សំណូមពររបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធដែលមិនពេញចិត្តនឹងការគ្រប់គ្រងការផ្តល់សេវាសម្អាត ការប្រមូល និងការដឹកជញ្ជូនសំរាម ការប្រើប្រាស់ និងការគ្រប់គ្រងទីលានទុកដាក់សំរាម ព្រមទាំងផលប៉ះពាល់លើជីវភាពរស់នៅរបស់អ្នកអាស្រ័យផលនៅទីលានទុកដាក់សំរាម ដែលស្ថិតនៅក្រោមសមាសភាគទី២នៃគម្រោងធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្លាស្ទិកនៅប្រទេសកម្ពុជាក្រោមក្របខ័ណ្ឌហិរញ្ញប្បទានរបស់ធនាគារពិភពលោក។

បណ្តឹងតវ៉ា និងសំណើ សំណូមពរដែលពាក់ព័ន្ធនឹងការដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ បណ្តឹងតវ៉ា និងសំណើ សំណូមពរពាក់ព័ន្ធនឹងការកសាងហេដ្ឋារចនាសម្ព័ន្ធទីលានចាក់សំរាម ដែលស្ថិតក្រោមក្របខ័ណ្ឌនៃការអនុវត្តគម្រោងធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្លាស្ទិកនៅប្រទេសកម្ពុជា មិនស្ថិតនៅក្នុងវិសាលភាពនៃសេចក្តីណែនាំស្តីពីនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ា និងសំណើ សំណូមពររបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនេះទេ។ បណ្តឹងតវ៉ា និងសំណើ សំណូមពរដែលពាក់ព័ន្ធការដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ គឺជាសមត្ថកិច្ចរបស់គណៈកម្មការដោះស្រាយបណ្តឹងតវ៉ាថ្នាក់ខេត្ត ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ចេញលិខិតណែនាំដល់រដ្ឋបាលខេត្តគោលដៅនាពេលកន្លងមក។ ដោយឡែក បណ្តឹងតវ៉ា និងសំណើ សំណូមពរដែលពាក់ព័ន្ធការកសាងហេដ្ឋារចនាសម្ព័ន្ធទីលានចាក់សំរាម គឺស្ថិតនៅក្រោមសមត្ថកិច្ចដោះស្រាយរបស់យន្តការ ដែលត្រូវរៀបចំដោយក្រសួងសាធារណការ និងដឹកជញ្ជូន។

## ២. សញ្ញាណនៃបណ្តឹងតវ៉ា និងសំណើ សំណូមពរ

**បណ្តឹងតវ៉ា៖** នៅក្នុងបរិបទនៃគម្រោងធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្លាស្ទិកនៅប្រទេសកម្ពុជា បណ្តឹងតវ៉ាសំដៅដល់(១)ការសម្តែងភាពមិនពេញចិត្តចំពោះការផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមដែលមិនបានអនុវត្តត្រឹមត្រូវ (២)ការគ្រប់គ្រង និងការប្រើប្រាស់ទីលានដែលអនុវត្តមិនស្របតាមលិខិតបទដ្ឋាន ស្តង់ដា និងនីតិវិធី (៣)ការបង្កផលប៉ះពាល់លើជីវភាពរស់នៅរបស់អ្នកអាស្រ័យផលនៅទីលានចាក់សំរាម និង(៤)ការប្រព្រឹត្តអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

បណ្តឹងតវ៉ា មានលក្ខណៈទាមទារសំណង ឬចង់ឱ្យមានការកែប្រែ ឬធ្វើឱ្យប្រសើរឡើងនូវអាកប្បកិរិយារបស់បុគ្គលិកពាក់ព័ន្ធនៅក្នុងដំណើរការនៃការអនុវត្តគម្រោងធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្លាស្ទិកនៅប្រទេសកម្ពុជា។

រាល់បណ្តឹងតវ៉ាដូចមានចែងខាងលើ ត្រូវមានកម្មវត្ថុ និងការបញ្ជាក់អំពីអង្គហេតុ និងភស្តុតាងត្រឹមត្រូវច្បាស់លាស់។

**សំណើ សំណូមពរ៖** សំដៅដល់ការលើកឡើងនូវមតិយោបល់ ឬការយល់ឃើញ ការផ្តល់ព័ត៌មាន ឬការស្នើសុំ ដែលពាក់ព័ន្ធនឹងការអនុវត្តគម្រោងក្នុងគោលបំណងដើម្បីឱ្យស្ថាប័ន ឬអង្គភាពដែលមានសមត្ថកិច្ចទទួលខុសត្រូវធ្វើការកែលម្អ ឬធ្វើការដោះស្រាយ។

បណ្តឹងតវ៉ា និងសំណើ សំណូមពរអាចបង្ហាញអត្តសញ្ញាណ ឬមិនបង្ហាញអត្តសញ្ញាណ៖

- **បង្ហាញអត្តសញ្ញាណ៖** សំដៅដល់បណ្តឹងតវ៉ា និងសំណើ សំណូមពរដែលមានបង្ហាញឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬអ្នកស្នើសុំច្បាស់លាស់។
- **មិនបង្ហាញអត្តសញ្ញាណ៖**សំដៅដល់បណ្តឹងតវ៉ា និងសំណើ សំណូមពរដែលមិនបានបង្ហាញឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬអ្នកស្នើសុំច្បាស់លាស់។

## ៣. គោលការណ៍រួម

នៅក្នុងដំណើរការអនុវត្តនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ា និងសំណើ សំណូមពររបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ចម្បងៗ រួមមាន៖

+ **នីត្យានុកូលភាព** ៖ រាល់បណ្តឹងតវ៉ា និងសំណើ សំណូមពររបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ ត្រូវធ្វើការដោះស្រាយស្របតាមគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ជាធរមាន។

+ **គណនេយ្យភាព** ៖ សំដៅដល់ការទទួលខុសត្រូវខ្ពស់ចំពោះការចាត់វិធានការដោះស្រាយបណ្តឹងតវ៉ា និងសំណើ សំណូមពរដែលទទួលបានពីប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា ដោយមិនត្រូវទុកករណីណាមួយចោលមិនដោះស្រាយ។ លទ្ធផលនៃការដោះស្រាយបណ្តឹងតវ៉ា ត្រូវបានផ្តល់ព័ត៌មានត្រឡប់ជូនម្ចាស់បណ្តឹងវិញ ឬផ្សព្វផ្សាយជាសាធារណៈ។

+ **តម្លាភាព** ៖ សំដៅដល់ការដោះស្រាយបណ្តឹងតវ៉ា និងសំណើ សំណូមពរដោយអនុលោមតាមគោលការណ៍ណែនាំ នីតិវិធី និងបែបបទដែលបានកំណត់ដោយគ្មានការរើសអើង។

+ **សាមញ្ញ** ៖ សំដៅដល់ការរៀបចំនីតិវិធី និងបែបបទនៃការទទួលសម្រុះសម្រួល ដោះស្រាយឱ្យមានលក្ខណៈសាមញ្ញ មិនស្មុគស្មាញ និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការមកទំនាក់ទំនង ព្រមទាំងទទួលការឆ្លើយតប និងផ្តល់ព័ត៌មានត្រឡប់ឆាប់រហ័សទាន់ពេលវេលា។

+ **រក្សាការសម្ងាត់** ៖ សំដៅដល់ការមិនបញ្ចេញឈ្មោះអ្នកប្តឹង ឬប្រជាពលរដ្ឋដែលបានផ្តល់ព័ត៌មានសំណើ សំណូមពរដល់អ្នកពាក់ព័ន្ធនានា ឬដល់អ្នកត្រូវគេប្តឹង។ នៅក្នុងដំណើរការពិនិត្យ ស្រាវជ្រាវបណ្តឹងតវ៉ា និងសំណើ សំណូមពរ ត្រូវរក្សាការសម្ងាត់នូវអត្តសញ្ញាណរបស់អ្នកប្តឹង និងអ្នកត្រូវគេប្តឹង។ កំណត់សម្គាល់៖ ចំពោះលទ្ធផលរកឃើញពាក់ព័ន្ធអ្នកត្រូវគេប្តឹង ដែលបានប្រព្រឹត្ត ឬមិនបានប្រព្រឹត្តកំហុសធ្ងន់ដូចការចោទប្រកាន់ រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់អាចធ្វើការផ្សព្វផ្សាយដល់សាធារណជនអំពីលទ្ធផលរកឃើញទាំងនោះ។

## ៤. យន្តការទទួលបណ្តឹងតវ៉ា និងសំណើ សំណូមពរ

រដ្ឋបាលខេត្តគោលដៅនៃគម្រោង ត្រូវចាត់មន្ត្រីនៃរដ្ឋបាលខេត្តឱ្យទទួលបន្ទុកក្នុងការទទួលបណ្តឹងតវ៉ា និងសំណើ សំណូមពរពាក់ព័ន្ធនឹងការគ្រប់គ្រង និងការប្រើប្រាស់ទីលានទុកដាក់សំរាម ព្រមទាំងផលប៉ះពាល់លើជីវភាពរស់នៅរបស់អ្នកអាស្រ័យផលនៅទីលានទុកដាក់សំរាម។

រដ្ឋបាលក្រុង ស្រុកគោលដៅនៃគម្រោង ត្រូវចាត់មន្ត្រីទទួលបន្ទុកកិច្ចការសង្គម និងមន្ត្រីពាក់ព័ន្ធនៃក្រុមការងារបច្ចេកទេសគាំទ្រការអនុវត្តគម្រោងធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្លាស្ទិកនៅប្រទេសកម្ពុជា ដើម្បីទទួលបណ្តឹងតវ៉ា និងសំណើ សំណូមពរ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងការផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម ព្រមទាំងផលប៉ះពាល់លើជីវភាពរស់នៅរបស់អ្នកអាស្រ័យផលនៅទីលានទុកដាក់សំរាម។

រដ្ឋបាលឃុំ សង្កាត់ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរដ្ឋបាលក្រុង ស្រុកគោលដៅនៃការអនុវត្តគម្រោង មានតួនាទីជួយរដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុកសាមីក្នុងការទទួលបណ្តឹងតវ៉ា និងសំណើ សំណូមពរ ហើយអាចសម្រុះសម្រួលដោះស្រាយបណ្តឹងតវ៉ា និងសំណើ សំណូមពរផ្អែកតាមការប្រគល់សិទ្ធិអំណាចពីរដ្ឋបាលក្រុង ស្រុកសាមីតាមករណីជាក់ស្តែង។

អភិបាលខេត្ត អភិបាលក្រុង ស្រុក និងមេឃុំ ចៅសង្កាត់ ត្រូវចាត់ចែងរៀបចំទីកន្លែង ឧបករណ៍ សម្ភារឱ្យបានគ្រប់គ្រាន់សម្រាប់គាំទ្រលើការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងតវ៉ា និងសំណើ សំណូមពរពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ។

## ៥. ភារកិច្ច

ក្នុងក្របខ័ណ្ឌនៃការអនុវត្តគម្រោងធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្លាស្ទិកនៅប្រទេសកម្ពុជា រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ មានភារកិច្ច ដូចខាងក្រោម៖

- ធ្វើការផ្សព្វផ្សាយអំពីភារកិច្ច មធ្យោបាយ ទីកន្លែងទទួលបណ្តឹងតវ៉ា និងសំណើ សំណូមពរឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ
- អនុវត្តគោលការណ៍ណែនាំ បែបបទ និងនីតិវិធីដែលបានកំណត់នៅក្នុងសេចក្តីណែនាំស្តីពីនីតិវិធីដោះស្រាយបណ្តឹងតវ៉ា និងសំណើ សំណូមពរឱ្យបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព
- ទទួលបណ្តឹងតវ៉ា និងសំណើ សំណូមពរដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ
- កត់ត្រាបណ្តឹងតវ៉ា និងសំណើ សំណូមពរដែលទទួលបានពីប្រជាពលរដ្ឋនៅក្នុងទម្រង់ដែលបានណែនាំឱ្យបានត្រឹមត្រូវ និងច្បាស់លាស់
- ចាត់ចែង សម្រុះសម្រួល ឬធ្វើការស្រាវជ្រាវលើករណីបណ្តឹងតវ៉ា និងសំណើ សំណូមពរ ដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរៀងៗខ្លួន
- ចាត់វិធានការដោះស្រាយទៅលើករណីបណ្តឹងតវ៉ា និងសំណើ សំណូមពរនីមួយៗ ដោយផ្អែកលើមូលដ្ឋាននៃការស្រាវជ្រាវ និងភស្តុតាងជាក់ស្តែងត្រឹមត្រូវ និងច្បាស់លាស់
- ស្នើសុំកិច្ចសហការពីស្ថាប័ន អង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចាត់វិធានការដោះស្រាយបណ្តឹងតវ៉ា និងសំណើ សំណូមពរ
- ឆ្លើយតប និងផ្តល់ព័ត៌មានត្រឡប់អំពីលទ្ធផលនៃការដោះស្រាយបណ្តឹងតវ៉ា និងសំណើ សំណូមពរ
- គ្រប់គ្រង និងទុកដាក់ឯកសារពាក់ព័ន្ធករណីបណ្តឹងតវ៉ាឱ្យបានត្រឹមត្រូវ និងរក្សាការសម្ងាត់នូវរាល់ព័ត៌មានរបស់បុគ្គល
- ធ្វើសេចក្តីរាយការណ៍ជាប្រចាំជូនមកក្រសួងមហាផ្ទៃអំពីលទ្ធផលនៃការដោះស្រាយបណ្តឹងតវ៉ា និងសំណើ សំណូមពរ។

រដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង ស្រុកអាចធ្វើប្រតិភូកម្មសិទ្ធិអំណាចក្នុងការអនុវត្តភារកិច្ចណាមួយរបស់ខ្លួនឱ្យទៅរដ្ឋបាលឃុំ សង្កាត់ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីសម្រុះសម្រួលដោះស្រាយបណ្តឹងតវ៉ា និងសំណើ សំណូមពររបស់ប្រជាពលរដ្ឋតាមករណីជាក់ស្តែង។

## ៦. សមត្ថកិច្ច

**រដ្ឋបាលខេត្តគោលដៅ** មានសមត្ថកិច្ចដោះស្រាយបណ្ដឹងតវ៉ា និងសំណើ សំណូមពរដែលពាក់ព័ន្ធនឹង៖

- **ការគ្រប់គ្រង និងការប្រើប្រាស់ទីលានទុកដាក់សំរាម៖** សំដៅដល់ការអនុវត្តមិនស្របតាមលិខិតបទដ្ឋាន ស្តង់ដា និងនីតិវិធីនៃការគ្រប់គ្រងទីលានទុកដាក់សំរាម
- **ផលប៉ះពាល់លើជីវភាពរស់នៅរបស់អ្នកអាស្រ័យផលនៅទីលានទុកដាក់សំរាម៖** សំដៅដល់ការមិនពេញចិត្តរបស់អ្នកអាស្រ័យផលនៅលើទីលានចាក់សំរាមចំពោះវិធានការដោះស្រាយរបស់រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក ឬអាជ្ញាធរពាក់ព័ន្ធ។

**រដ្ឋបាលក្រុង ស្រុកគោលដៅ** មានសមត្ថកិច្ចដោះស្រាយបណ្ដឹងតវ៉ា និងសំណើ សំណូមពរ ដែលពាក់ព័ន្ធនឹង៖

- **សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម៖** សំដៅដល់សេវាកម្មដែលអនុវត្តមិនបានល្អ គ្មានគុណភាព មិនអនុលោមតាមពេលវេលាកំណត់ ឬមិនស្របតាមបទដ្ឋានបច្ចេកទេសពាក់ព័ន្ធនឹងអនាម័យបរិស្ថាន
- **ផលប៉ះពាល់លើជីវភាពរស់នៅរបស់អ្នកអាស្រ័យផលនៅទីលានទុកដាក់សំរាម៖** សំដៅដល់ការមិនពេញចិត្តរបស់អ្នកអាស្រ័យផលនៅលើទីលានចាក់សំរាមចំពោះវិធានការដោះស្រាយរបស់រដ្ឋបាលក្រុង ស្រុក ឬអាជ្ញាធរពាក់ព័ន្ធ។

**រដ្ឋបាលឃុំ សង្កាត់គោលដៅ** មានសមត្ថកិច្ចដោះស្រាយលើបណ្ដឹងតវ៉ា និងសំណើ សំណូមពរមួយចំនួនតាមរយៈការប្រគល់សិទ្ធិអំណាចពីរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង ស្រុកសាមីតាមករណីជាក់ស្ដែង។

ក្រៅពីសមត្ថកិច្ចខាងលើ រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ អាចទទួលសម្រុះសម្រួលដោះស្រាយបណ្ដឹងតវ៉ា និងសំណើ សំណូមពរពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ លើកលែងតែបណ្ដឹងតវ៉ានោះពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ និងច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។

## ៧. ដំណើរការនៃការដោះស្រាយបណ្ដឹងតវ៉ា និងសំណើ សំណូមពរ

រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់គោលដៅនៃគម្រោង ត្រូវអនុវត្តដំណើរការនៃការទទួលសម្រុះសម្រួលដោះស្រាយបណ្ដឹងតវ៉ា និងសំណើ សំណូមពរតាមនីតិវិធីដូចបានកំណត់ខាងក្រោម៖

### ៧.១. ការដាក់បណ្ដឹងតវ៉ា និងសំណើ សំណូមពរ

ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាមានសិទ្ធិដាក់បណ្ដឹងតវ៉ា និងសំណើ សំណូមពរផ្សេងៗពាក់ព័ន្ធនឹងការអនុវត្តគម្រោងធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្លាស្ទិកនៅប្រទេសកម្ពុជាដោយឥតគិតថ្លៃ។

ប្រជាពលរដ្ឋអាចដាក់បណ្ដឹងតវ៉ា និងសំណើ សំណូមពរដោយផ្ទាល់នៅទីតាំងដែលបានកំណត់ និងរៀបចំដោយរដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់គោលដៅនៃការអនុវត្តគម្រោង ដោយប្រើប្រាស់ទម្រង់បណ្ដឹងតវ៉ា និងសំណើ សំណូមពរដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១។ នៅក្នុងករណីប្រជាពលរដ្ឋ

ពុំអាចបំពេញទម្រង់បណ្ដឹងតវ៉ា និងសំណើ សំណូមពរដោយខ្លួនឯងបាន មន្ត្រីទទួលបន្ទុកត្រូវជួយបំពេញជំនួសទៅតាមទម្រង់ដែលបានកំណត់។

ក្រៅពីការជួបផ្ទាល់ ប្រជាពលរដ្ឋអាចដាក់បណ្ដឹងតវ៉ា និងសំណើ សំណូមពរតាមរយៈទូរសព្ទ តាមបណ្ដាញសង្គម ឬតាមមធ្យោបាយផ្សេងៗទៀតដែលបានរៀបចំដោយរដ្ឋបាលសាមីនីមួយៗ។

រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់នៃគម្រោងត្រូវធ្វើការផ្សព្វផ្សាយលេខទំនាក់ទំនងរបស់មន្ត្រីទទួលបន្ទុក ទីកន្លែង និងមធ្យោបាយទទួលបណ្ដឹងតវ៉ា និងសំណើ សំណូមពរ ព្រមទាំងយន្តការសម្រុះសម្រួលដោះស្រាយបណ្ដឹងតវ៉ា និងសំណើ សំណូមពរឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ។

**៧.២. ការកត់ត្រា និងការវាយតម្លៃ**

នៅពេលទទួលបានបណ្ដឹងតវ៉ា និងសំណើ សំណូមពរពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ មន្ត្រីទទួលបន្ទុកត្រូវធ្វើការកត់ត្រាភ្លាមៗ និងឱ្យបានត្រឹមត្រូវដោយប្រើប្រាស់ទម្រង់កត់ត្រា និងវាយតម្លៃបណ្ដឹងតវ៉ា និងសំណើ សំណូមពរដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី២។ ការកត់ត្រាបណ្ដឹងតវ៉ា និងសំណើ សំណូមពរគួរផ្ដោតលើ៖

+ **លេខរៀង៖** កត់ត្រាលំដាប់លេខរៀងនៃបណ្ដឹងតវ៉ា និងសំណើ សំណូមពរ
+ **កាលបរិច្ឆេទទទួល៖** ថ្ងៃខែឆ្នាំទទួលបណ្ដឹងតវ៉ា និងសំណើ សំណូមពរ
+ **ខ្លឹមសារសង្ខេប ៖** សរសេរខ្លឹមសារខ្លីៗនៃបណ្ដឹងតវ៉ា និងសំណើ សំណូមពរ
+ **មធ្យោបាយទទួល៖** តាមរយៈមធ្យោបាយណាមួយ
+ **ប្រភេទ៖** បណ្ដឹងតវ៉ា ឬសំណើ សំណូមពរ។

មន្ត្រីទទួលបន្ទុកនៃរដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់សាមីត្រូវធ្វើការពិនិត្យវាយតម្លៃបណ្ដឹងតវ៉ា និងសំណើ សំណូមពរ ដើម្បីកំណត់អំពីប្រភេទបណ្ដឹងតវ៉ា ឬសំណើ សំណូមពរ រួចដាក់ជូនអភិបាលខេត្ត អភិបាលក្រុង ស្រុក និងមេឃុំ ចៅសង្កាត់ ពិនិត្យ និងចាត់វិធានការដោះស្រាយ។

ការកត់ត្រា និងការវាយតម្លៃបណ្ដឹងតវ៉ា និងសំណើ សំណូមពរ ត្រូវធ្វើឡើងយ៉ាងយូរត្រឹម**រយៈពេល១ថ្ងៃនៃថ្ងៃធ្វើការ**។

**៧.៣. ការចាត់វិធានការដោះស្រាយ**

ការចាត់វិធានការដោះស្រាយលើករណីបណ្ដឹងតវ៉ា និងសំណើ សំណូមពរនីមួយៗ ត្រូវអនុវត្តឱ្យបានសមស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន កិច្ចសន្យា ស្តង់ដា ឬនីតិវិធីដែលបានកំណត់នៅក្នុងដំណើរការនៃការអនុវត្តគម្រោងធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្លាស្ទិកនៅប្រទេសកម្ពុជា។

រាល់ការចាត់វិធានការដោះស្រាយលើករណីបណ្ដឹងតវ៉ា និងសំណើ សំណូមពរនីមួយៗ**មិនត្រូវឱ្យលើសពីរយៈពេល១០ថ្ងៃនៃថ្ងៃធ្វើការ** គិតចាប់តាំងពីថ្ងៃដែលទទួលបណ្ដឹងតវ៉ា និងសំណើ សំណូមពរ។

អភិបាលខេត្ត អភិបាលក្រុង ស្រុក និងមេឃុំ ចៅសង្កាត់ត្រូវអនុវត្តឱ្យបានហ្មត់ចត់ និងទទួលខុសត្រូវខ្ពស់ចំពោះវិធានការដែលបានដាក់ចេញ ដើម្បីបង្កើនទំនុកចិត្តពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ។

នៅពេលទទួលបានបណ្ដឹងតវ៉ា និងសំណើ សំណូមពរពីមន្ត្រីទទួលបន្ទុក អភិបាលខេត្ត អភិបាលក្រុង ស្រុក និងមេឃុំ ចៅសង្កាត់ ត្រូវធ្វើការពិនិត្យខ្លឹមសារបណ្ដឹងតវ៉ា សំណើ សំណូមពរ និងឯកសារពាក់ព័ន្ធដោយត្រូវចាត់វិធានការដោះស្រាយដូចខាងក្រោម៖

- **ការឆ្លើយតប៖** ករណីបណ្ដឹងតវ៉ា និងសំណើ សំណូមពរផ្សេងៗដែលពុំមានភាពចាំបាច់ ត្រូវធ្វើការសម្រុះសម្រួល ឬស្រាវជ្រាវស្វែងរកការពិត
- **ស្រាវជ្រាវស្វែងរកការពិត៖** ករណីបណ្ដឹងតវ៉ា និងសំណើ សំណូមពរផ្សេងៗដែលមានភាពស្មុគស្មាញ និងមិនអាចធ្វើការឆ្លើយតបបានភ្លាមៗ ត្រូវចាត់ចែងណែនាំដល់អង្គភាព ឬមន្ត្រីពាក់ព័ន្ធឱ្យធ្វើការស្រាវជ្រាវរកអង្គហេតុ និងភស្តុតាងឱ្យបានត្រឹមត្រូវច្បាស់លាស់ រួចធ្វើការដោះស្រាយបណ្ដឹងតវ៉ា និងសំណើ សំណូមពរពាក់ព័ន្ធទៅនឹងករណីនីមួយៗ។

  ចំពោះបណ្ដឹងតវ៉ា និងសំណើ សំណូមពរពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលមានលក្ខណៈតូចតាច រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់គោលដៅនៃគម្រោងត្រូវយកចិត្តទុកដាក់ពិនិត្យ និងវិនិច្ឆ័យលើស្ថានភាព ហេតុ និងបច្ច័យនៃអំពើក្នុងបណ្ដឹងតវ៉ាឱ្យបានហ្មត់ចត់ មុននឹងសម្រុះសម្រួលដោះស្រាយ។ ក្នុងករណីពិនិត្យឃើញថាស្ថានភាពនៃអំពើមានលក្ខណៈជាបទឧក្រិដ្ឋ ឬបទមជ្ឈិមធ្ងន់ធ្ងរ រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់គោលដៅនៃគម្រោង ត្រូវបញ្ជូនបណ្ដឹងតវ៉ានេះទៅស្ថាប័នមានសមត្ថកិច្ច ដើម្បីពិនិត្យ និងចាត់វិធានការតាមនីតិវិធីច្បាប់ជាធរមាន។

  រាល់ការស្រាវជ្រាវបណ្ដឹងតវ៉ា និងសំណើ សំណូមពរនីមួយៗត្រូវរៀបចំជារបាយការណ៍ស្របតាមទម្រង់ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៣ ឱ្យបានត្រឹមត្រូវច្បាស់លាស់អំពីលទ្ធផលនៃការស្រាវជ្រាវបណ្ដឹងតវ៉ា និងសំណើ សំណូមពរ។
- **ការបញ្ជូនទៅស្ថាប័ន អង្គភាពមានសមត្ថកិច្ច៖** ចំពោះបណ្ដឹងតវ៉ា និងសំណើ សំណូមពរ ដែលមិនស្ថិតក្នុងសមត្ថកិច្ចដូចបានកំណត់នៅក្នុងចំណុចទី៦នៃសេចក្ដីណែនាំនេះ ត្រូវចាត់បញ្ជូនទៅស្ថាប័នអង្គភាពមានសមត្ថកិច្ច ដើម្បីពិនិត្យ និងដោះស្រាយ
- **ការបិទសំណុំរឿងមិនចាត់ការ ៖** ក្នុងករណីបណ្ដឹងតវ៉ា និងសំណើ សំណូមពរដែលពុំមានកម្មវត្ថុ អង្គហេតុ និងភស្តុតាងត្រឹមត្រូវច្បាស់លាស់ ឬករណីមានសំណើសុំដកបណ្ដឹងតវ៉ាពីអ្នកប្ដឹង ឬករណីបណ្ដឹងតវ៉ាដែលកំពុងស្ថិតក្នុងដំណើរការដោះស្រាយរបស់ស្ថាប័នមានសមត្ថកិច្ចណាមួយ។

ចំពោះករណីបណ្ដឹងតវ៉ា និងសំណើ សំណូមពរផ្សេងៗ ដែលស្ថិតក្នុងសមត្ថកិច្ច និងមានភាពស្មុគស្មាញមិនអាចដោះស្រាយបាន រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់គោលដៅនៃគម្រោងត្រូវអនុវត្តដូចខាងក្រោម៖

- **បណ្ដឹងតវ៉ា និងសំណើ សំណូមពរដែលទទួលបានដោយរដ្ឋបាលឃុំ សង្កាត់៖** មេឃុំ ចៅសង្កាត់ត្រូវចាត់ចែងបញ្ជូនបណ្ដឹងតវ៉ា និងសំណើ សំណូមពរនានាដែលរដ្ឋបាលឃុំ សង្កាត់ពុំមានលទ្ធភាពដោះស្រាយ ឬមិនស្ថិតក្រោមសិទ្ធិអំណាចរបស់ខ្លួនទៅរដ្ឋបាលក្រុង ស្រុក ឬរដ្ឋបាលខេត្ត មានសមត្ថកិច្ច ដើម្បីចាត់វិធានការដោះស្រាយ។

- **បណ្តឹងតវ៉ា និងសំណើ សំណូមពរ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក៖** អភិបាលក្រុង ស្រុក ត្រូវស្នើសុំគោលការណ៍ពីអភិបាលខេត្តដើម្បីចាត់វិធានការដោះស្រាយចំពោះបណ្តឹងតវ៉ា ឬសំណើ សំណូមពរដែលរដ្ឋបាលខ្លួនពុំអាចដោះស្រាយបាន។
- **បណ្តឹងតវ៉ា និងសំណើ សំណូមពរ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់រដ្ឋបាលខេត្ត៖** អភិបាលខេត្ត ត្រូវធ្វើរបាយការណ៍ និងស្នើសុំគោលការណ៍ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីដាក់ចេញវិធានការដោះស្រាយបណ្តឹងតវ៉ា ឬសំណើ សំណូមពរដែលរដ្ឋបាលខ្លួនពុំអាចដោះស្រាយបាន។

ការចាត់វិធានការដោះស្រាយបណ្តឹងតវ៉ា និងសំណើ សំណូមពររួមមានដូចជា៖

+ ធ្វើការណែនាំ ឬស្នើសុំចាត់វិធានការចំពោះបុគ្គលិកក្រុមហ៊ុនសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម ដោយផ្អែកតាមកិច្ចសន្យា ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
+ អនុវត្តវិធានការរដ្ឋបាលចំពោះមន្ត្រីរាជការស៊ីវិល ស្របតាមសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ឬមន្ត្រីជាប់កិច្ចសន្យានានាស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
+ ដាក់ចេញសេចក្តីជូនដំណឹង ដើម្បីធ្វើការផ្សព្វផ្សាយជាសាធារណៈ ឬបញ្ជាក់អំពីគោលការណ៍ណែនាំ បែបបទ និងនីតិវិធីដែលមានចែងជាធរមាន
+ អនុវត្តបទបញ្ជាផ្ទៃក្នុង ឬដាក់ចេញគោលការណ៍បន្ថែមដើម្បីកែលម្អការគ្រប់គ្រងរបស់អង្គភាពការិយាល័យ ឬបុគ្គលដែលបានប្រព្រឹត្តខុស
+ ស្នើសុំកិច្ចសហការ ឬការគាំទ្រពីស្ថាប័ន អង្គភាពពាក់ព័ន្ធដើម្បីពិនិត្យ ឬកែសម្រួលបែបបទ និងនីតិវិធី
+ ចាត់វិធានការជួយសម្របសម្រួល និងផ្តល់ការគាំទ្រដល់ប្រជាពលរដ្ឋដែលទទួលរងគ្រោះ ឬត្រូវបានគេរំលោភបំពាន ដើម្បីទទួលបានសំណង ឬដំណោះស្រាយសមស្រប។

វិធានការដោះស្រាយចំពោះបណ្តឹងតវ៉ា និងសំណើ សំណូមពរ ស្ថិតក្នុងក្របខ័ណ្ឌនៃសេចក្តីណែនាំនេះ ពុំរារាំងសិទ្ធិរបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធក្នុងការប្តឹងតវ៉ា និងទាមទារទៅកាន់ស្ថាប័នតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជានោះឡើយ។

**៧.៤. ការតាមដាន និងការផ្តល់ព័ត៌មានត្រឡប់**

មន្ត្រីទទួលបន្ទុកត្រូវធ្វើការកត់ត្រានូវរាល់លទ្ធផលនៃការដោះស្រាយបណ្តឹងតវ៉ា និងសំណើ សំណូមពរឱ្យបានត្រឹមត្រូវ និងច្បាស់លាស់ដើម្បីតាមដាននូវដំណើរការនៃការដោះស្រាយបណ្តឹងតវ៉ា និងសំណើ សំណូមពរនីមួយៗ។

អភិបាលខេត្ត អភិបាលក្រុង ស្រុក និងមេឃុំ ចៅសង្កាត់ត្រូវចាត់ចែងផ្តល់ព័ត៌មានត្រឡប់អំពីលទ្ធផលនៃការសម្រុះសម្រួលដោះស្រាយបណ្តឹងតវ៉ា និងសំណើ សំណូមពរជូនម្ចាស់បណ្តឹងតវ៉ា ឬម្ចាស់សំណើ សំណូមពរឱ្យបានឆាប់រហ័ស **យ៉ាងយូរត្រឹមរយៈពេល២ថ្ងៃនៃថ្ងៃធ្វើការ** ក្រោយពីរដ្ឋបាលបានចាត់វិធានការដោះស្រាយបណ្តឹងតវ៉ា និងសំណើ សំណូមពរនោះចប់សព្វគ្រប់។

ការផ្ដល់ព័ត៌មានត្រឡប់អាចធ្វើឡើងតាមរយៈ៖

+ ទំនាក់ទំនងតាមទូរសព្ទ ដើម្បីជម្រាបជូនអំពីលទ្ធផលនៃការដោះស្រាយបណ្ដឹងតវ៉ា និង សំណើ សំណូមពរ
+ អញ្ជើញភាគីមកជួបផ្ទាល់ ក្នុងករណីចាំបាច់
+ បិទផ្សាយ ឬផ្សព្វផ្សាយតាមបណ្ដាញទំនាក់ទំនងសង្គម ឬតាមមធ្យោបាយផ្សេងៗ ដោយ មិនត្រូវបង្ហាញអត្តសញ្ញាណរបស់អ្នកប្ដឹង ឬម្ចាស់សំណើ សំណូមពរ
+ ផ្ដល់ព័ត៌មានដល់អាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ។

**៧.៥. ការគ្រប់គ្រង និងការទុកដាក់ឯកសារ**

អភិបាលខេត្ត អភិបាលក្រុង ស្រុក និងមេឃុំ ចៅសង្កាត់ ត្រូវចាត់ចែងឱ្យមានការគ្រប់គ្រងរក្សាទុក ឯកសារនានាពាក់ព័ន្ធបណ្ដឹងតវ៉ា និងសំណើ សំណូមពរឱ្យបានត្រឹមត្រូវ ដោយត្រូវរក្សាទុកជាការសម្ងាត់ ។

រាល់បណ្ដឹងតវ៉ា និងសំណើ សំណូមពរដែលពាក់ព័ន្ធអំពើហិង្សាទាក់ទងនឹងយេនឌ័រ មន្ត្រីទទួលបន្ទុក ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ដោយមិនត្រូវបង្ហាញអត្តសញ្ញាណ ឬធ្វើឱ្យបែកធ្លាយព័ត៌មានបុគ្គល ដែលជា ជនរងគ្រោះតាមរយៈបណ្ដាញសង្គម ឬប្រកពណាមួយនោះឡើយ។

ទទួលបានសេចក្ដីណែនាំនេះ គ្រប់អង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ និងគ្រប់រដ្ឋបាលថ្នាក់ ក្រោមជាតិដែលជាគោលដៅនៃការអនុវត្តគម្រោងធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹង និង សំណល់ប្លាស្ទិកនៅប្រទេសកម្ពុជា ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ចន្ទ ១៤កើត ខែ បុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល ៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងបរិស្ថាន
- ក្រសួងយុត្តិធម៌
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ
- រដ្ឋបាលខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់គោលដៅ
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១៖ទម្រង់បណ្តឹងតវ៉ា និងសំណើ សំណូមពរ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>បណ្តឹងតវ៉ា និងសំណើ សំណូមពរ</u>**

ខ្ញុំបាទ ឬនាងខ្ញុំឈ្មោះ................................សញ្ជាតិ............អាយុ.......... មុខរបរ.....................
ទីលំនៅបច្ចុប្បន្ន នៅផ្ទះលេខ........... ផ្លូវលេខ............ ភូមិ...................... ឃុំ សង្កាត់.........................
ក្រុង ស្រុក ខណ្ឌ.................. រាជធានី ខេត្ត......................... លេខទូរសព្ទ.............................។

**<u>កម្មវត្ថុ</u>** ៖ ..........................................................................................................................។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ ឬនាងខ្ញុំសូមគោរពជម្រាបជូនថា៖

..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រីប្រធាន មេត្តាពិនិត្យ និងដោះស្រាយករណីបណ្តឹងតវ៉ា សំណើ សំណូមពរខាងលើដោយក្តីអនុគ្រោះ។

សូម ឯកឧត្តម លោកជំទាវ លោក លោកស្រីប្រធាន ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ឬនាងខ្ញុំ។

ថ្ងៃទី.........ខែ............ឆ្នាំ................
ហត្ថលេខា ឬស្នាមមេដៃ

ឧបសម្ព័ន្ធទី២៖ ទម្រង់កត់ត្រា និងវាយតម្លៃបណ្តឹងតវ៉ា និងសំណើ សំណូមពរ

# កំណត់ត្រា និងវាយតម្លៃបណ្តឹងតវ៉ា និងសំណើ សំណូមពរ

| ល.រ | កាលបរិច្ឆេទទទួល | ខ្លឹមសារសង្ខេប | មធ្យោបាយទទួល | | | | ប្រភេទ | | ហត្ថលេខាអ្នកទទួល |
|---|---|---|---|---|---|---|---|---|---|
| | | | ជួបផ្ទាល់ | ទូរសព្ទ | បណ្តាញសង្គម | ផ្សេងៗ | បណ្តឹងតវ៉ា | សំណើ សំណូមពរ | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

ឧបសម្ព័ន្ធទី៣៖ ទម្រង់របាយការណ៍ស្តីពីការស្រាវជ្រាវបណ្តឹងតវ៉ា និងសំណើ សំណូមពរ

## របាយការណ៍ស្តីពីលទ្ធផលនៃការដោះស្រាយបណ្តឹងតវ៉ា និងសំណើ សំណូមពរ

### ១. អំពីបណ្តឹងតវ៉ា និងសំណើ សំណូមពរ

| ខ្លឹមសារសង្ខេប៖ |
|---|
| |

### ២. លទ្ធផលនៃការស្រាវជ្រាវ

ក្រោយពីការចុះស្រាវជ្រាវបណ្តឹងតវ៉ា និងសំណើ សំណូមពរ ក្រុមការងារទទួលបានលទ្ធផលដូចខាងក្រោម៖

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

### ៣. សេចក្តីសន្និដ្ឋាន និងការចាត់វិធានការដោះស្រាយ

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

................ ថ្ងៃទី......... ខែ.......... ឆ្នាំ..............

**ហត្ថលេខា**